**សលាកប័ត្រព័ត៌មាន៖** ឋានានុក្រមច្បាប់នៅកម្ពុជា
**ខ្លឹមសារសង្ខេប៖** លិខិតុបករណ៍គតិយុត្តជាតិ ស្របតាមឋានានុក្រមជាក់លាក់ដែលចាំបាច់ ត្រូវតែចងក្រងឡើងដោយគោរពតាមគោលការណ៍នីតិរដ្ឋ។ តែយ៉ាងណាក៏ដោយ មានករណីមួយចំនួន ដែលរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") មិនគោរពតាមឋានានុក្រមនេះ ហើយប្រើប្រាស់នូវលិខិតុបករណ៍គតិយុត្តដែលមានកម្រិតទាបដើម្បីគ្រប់គ្រងលើបញ្ហាសិទ្ធិមនុស្សជាមូលដ្ឋាន។

## សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះ ផ្តល់នូវទិដ្ឋភាពទូទៅនៃឋានានុក្រមច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") និងគូសបញ្ជាក់ពីករណីដែលលិខិតុបករណ៍គតិយុត្តជារឿយៗត្រូវបានគេប្រើប្រាស់ខុស ហេតុដូច្នេះហើយ បង្កឲ្យមានគ្រោះថ្នាក់ដល់គោលការណ៍នីតិរដ្ឋ។ សលាកប័ត្រព័ត៌មាននេះ គឺតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

## ច្បាប់ជាតិ

លិខិតុបករណ៍គតិយុត្តនីមួយៗ មានសុពលភាព និងសិទ្ធិអំណាចរបស់ខ្លួនទៅតាមរចនាសម្ព័ន្ធនៃឋានានុក្រមច្បាប់។ កាលណាត្រូវអនុម័តលិខិតុបករណ៍ដែលមានកម្រិតខ្ពស់ នីតិវិធីនៃការពិនិត្យលើលិខិតុបករណ៍នោះនឹងរឹតតែយូរ ហើយវិសាលភាពនៃភូមិសាស្ត្រដែលត្រូវគ្របដណ្តប់លើការអនុវត្តក៏កាន់តែទូលំទូលាយដែរ។ លិខិតុបករណ៍គតិយុត្តដែលមានកម្រិតទាបតាមផ្លូវច្បាប់ទាំងឡាយត្រូវតែស្របតាមលិខិតុបករណ៍គតិយុត្តដែលមានឋានានុក្រមខ្ពស់ជាង ឬបើមិនដូច្នោះទេ លិខិតគតិយុត្តទាំងនោះនឹងត្រូវកែប្រែ ឬក៏ប្រកាសថាពុំមានសុពលភាពអនុវត្តនោះទេ។

ឋានានុក្រមច្បាប់នៅកម្ពុជា គឺមានតាមលំដាប់លំដោយចាប់ពីកម្រិតខ្ពស់បំផុតរហូតដល់កម្រិតទាបបំផុត។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ ("រដ្ឋធម្មនុញ្ញ") គឺជាច្បាប់កំពូលនៅក្នុងប្រទេសកម្ពុជា។ រាល់ច្បាប់ ឯកសារគតិយុត្ត និងសេចក្តីសម្រេចរបស់ស្ថាប័នរដ្ឋទាំងឡាយត្រូវតែអនុលោមតាមរដ្ឋធម្មនុញ្ញ។ ច្បាប់ ត្រូវអនុម័តតាមរយៈរដ្ឋសភា និងព្រឹទ្ធសភា ហើយត្រូវប្រកាសឲ្យប្រើដោយព្រះមហាក្សត្រ ឬប្រមុខរដ្ឋស្តីទី។ ព្រះរាជក្រឹត្យ គឺជាបទបញ្ជាផ្នែកនីតិប្រតិបត្តិដែលចេញដោយព្រះមហាក្សត្រ បន្ទាប់ពីមានសំណើពីគណៈរដ្ឋមន្ត្រី ដើម្បីរៀបចំការប្រព្រឹត្តទៅរបស់ ស្ថាប័នរដ្ឋ បង្កើតស្ថាប័នរបស់រដ្ឋាភិបាលថ្មីណាមួយ ឬតែងតាំងមន្ត្រីរាជការជាន់ខ្ពស់ ឯកអគ្គរាជទូត និងចៅក្រម។ អនុក្រឹត្យ គឺត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់នូវបទប្បញ្ញត្តិនានានៅក្នុងច្បាប់ជាធរមានដោយចែងពីមុខងារ និងតួនាទីរបស់ស្ថាប័នរដ្ឋាភិបាល និងតែងតាំងមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល។ អនុក្រឹត្យត្រូវបានព្រាងឡើងដោយក្រសួងពាក់ព័ន្ធនានា ដែលត្រូវអនុម័តដោយគណៈរដ្ឋមន្ត្រី និងយល់ព្រមដោយនាយករដ្ឋមន្ត្រី។ អនុក្រឹត្យនេះ គឺជាសេចក្តីសម្រេចទូទៅរបស់រដ្ឋាភិបាល។ សេចក្តីបង្គាប់របស់រដ្ឋមន្ត្រី ឬប្រកាសរបស់

ក្រសួង (ប្រកាស) គឺជាបទបញ្ញាផ្នែកនីតិប្រតិបត្តិបង្កើតឡើងនៅថ្នាក់ក្រសួង ដើម្បីអនុវត្ត និងបញ្ជាក់ពីបទប្បញ្ញត្តិជាក់លាក់ដែលកំណត់នៅក្នុងឯកសារច្បាប់ដែលមានតម្លៃខ្ពស់ជាង និងផ្តល់ការណែនាំមួយចំនួន។ ដែនកំណត់នៃប្រកាសគឺមានវិសាលភាពក្នុងកម្មវត្ថុ ដែលជាដែនសមត្ថកិច្ចរបស់ក្រសួង ដែលបានអនុម័តតែប៉ុណ្ណោះ។ សេចក្តីសម្រេច គឺធ្វើឡើងដោយនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីពាក់ព័ន្ធ ហើយសេចក្តីសម្រេចនេះត្រូវបានប្រើប្រាស់សម្រាប់គោលបំណងណាមួយ ដែលមានលក្ខណៈជាបណ្តោះអាសន្ន។ សេចក្តីសម្រេចនេះអស់សុពលភាព ឬរលត់ទៅ នៅពេលសម្រេចគោលបំណងរបស់ខ្លួន។ សារាចរ គឺចេញដោយនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រី ដោយផ្តល់ការណែនាំពាក់ព័ន្ធទៅនឹងវិធានការផ្លូវច្បាប់ ឬគ្រប់គ្រងជាក់លាក់ ប៉ុន្តែ ពុំមានចំណងកាតព្វកិច្ចផ្លូវច្បាប់នោះទេ។ បទបញ្ញាថ្នាក់មូលដ្ឋាន ឬដីកា (ដីកា) ត្រូវចេញដោយក្រុមប្រឹក្សាមូលដ្ឋាននៅថ្នាក់ក្រោមជាតិ។ ដីកានេះមានអំណាចផ្លូវច្បាប់នៅក្នុងដែនយុត្តាធិការរបស់ក្រុមប្រឹក្សាមូលដ្ឋានដែលចេញដីកា ហេតុដូច្នេះ ដីកាមិនអាចផ្ទុយពីបទបញ្ញាផ្សេងទៀតនៅថ្នាក់ជាតិឡើយ។

**ច្បាប់អន្តរជាតិ**

មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញទទួលស្គាល់ និងគោរពសន្ធិសញ្ញានានាស្តីពីសិទ្ធិមនុស្សអន្តរជាតិ ជាផ្នែកនៃច្បាប់កម្ពុជា។ នៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ បានប្រកាសបញ្ជាក់ពីការអនុវត្តលិខិតុបករណ៍សិទ្ធិមនុស្សនៅក្នុងច្បាប់ជាតិ តាមរយៈការក្រើនរម្លឹកដល់ចៅក្រមថា ចៅក្រមមានកាតព្វកិច្ចក្នុងការពិចារណាលើច្បាប់កម្ពុជាទាំងអស់ រួមទាំង ច្បាប់អន្តរជាតិទាំងនោះផង នៅក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន។ យ៉ាងណាក៏ដោយ រដ្ឋធម្មនុញ្ញមិនបានចែងបញ្ជាក់ឲ្យច្បាស់លាស់ពីឋានៈនៃសន្ធិសញ្ញាអន្តរជាតិក្នុងឋានានុក្រមនៃប្រព័ន្ធច្បាប់កម្ពុជានោះទេ ហើយក៏មិនបានចែងពីករណីច្បាប់របស់តុលាការកម្ពុជា ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនោះដែរ។ យើងអាចសន្និដ្ឋានបានថា សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញ។ ដោយសារតែ សន្ធិសញ្ញាគួរតែត្រូវបានផ្តល់សច្ចាប័នតាមរយៈការបោះឆ្នោតនៅរដ្ឋសភា ដូចនេះ ការអនុម័តសន្ធិសញ្ញាត្រូវអនុវត្តតាមនីតិវិធីដូចការអនុម័តច្បាប់ជាតិដែរ ហេតុដូច្នេះហើយ សន្ធិសញ្ញាគួរតែខ្ពស់ជាង ឬយ៉ាងហោចណាស់ មានតម្លៃដូចគ្នានឹងច្បាប់ជាតិដែរ។

**ការប្រើប្រាស់លិខិតុបករណ៍ពុំត្រឹមត្រូវ**

តាមទ្រឹស្តី លិខិតុបករណ៍គតិយុត្តនីមួយៗ ត្រូវតែអនុវត្តតាមនីតិវិធីច្បាប់ជាក់លាក់ដើម្បីទទួលបាននូវសុពលភាព និងអំណាចក្នុងការអនុវត្ត។ យ៉ាងណាក្តី តាមការអនុវត្តជាក់ស្តែង មានការអនុម័តដោយប្រើវិធីសាស្ត្រខុសៗគ្នា។

គោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព គឺជាគោលនយោបាយមួយបង្កើតឡើងក្នុងឆ្នាំ២០១០ ដែលជាវិធានការដើម្បីកាត់បន្ថយបទល្មើសនៅថ្នាក់មូលដ្ឋាន និងពង្រឹងកិច្ចប្រតិបត្តិការរបស់នគរបាល។ គោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពនេះ មិនមែនជាច្បាប់ ដែលត្រូវអនុម័តដោយរដ្ឋសភា ប៉ុន្តែគោលនយោបាយនេះកើតចេញពីប្រកាសដែលចេញដោយក្រសួងមហាផ្ទៃ។ គោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព សំដៅអនុវត្តឲ្យមានការផ្លាស់ប្តូរជាមូលដ្ឋាន ក្នុងរយៈពេលវែង និងមានលក្ខណៈទូលំទូលាយនៅក្នុងសង្គម។ ហេតុដូច្នេះ

គោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព គួរតែត្រូវបានអនុវត្តដោយមានការអនុម័តតាមផ្លូវច្បាប់ឲ្យបានត្រឹមត្រូវ។ បន្ថែមលើនេះទៀត គោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពផ្ទុយទៅនឹងច្បាប់សំខាន់ៗជាច្រើនដែលខ្លួនសំដៅក្នុងការកាត់បន្ថយបទល្មើស ដូចជា ច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន បទប្បញ្ញត្តិមួយចំនួននៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ជាដើម។ គោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពក៏បង្ហាញពីការកាត់បន្ថយសិទ្ធិមួយចំនួនដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដូចជា សិទ្ធិជួបប្រជុំដោយសន្តិវិធីជាដើម។ ហេតុដូច្នេះ គោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពគួរតែត្រូវធ្វើវិសោធនកម្មដើម្បីឲ្យស្របតាមច្បាប់ដែលមានឋានានុក្រមខ្ពស់ជាង។ ផ្ទុយទៅវិញ អាជ្ញាមូលដ្ឋានជាច្រើនយល់ឃើញថា គោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពនេះមានអាទិភាព និងសំខាន់ជាងច្បាប់ដែលបានអនុម័តស្របតាមបែបលទ្ធិប្រជាធិបតេយ្យ។

ជាងនេះទៅទៀត យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋអាចធ្វើអនុប្បយោគប្រែក្លាយជាដីឯកជនរបស់រដ្ឋតាមច្បាប់អនុម័តដោយរដ្ឋសភា។ ទោះជាយ៉ាងណាក៏ដោយ ជារឿយៗ រដ្ឋាភិបាលចេញអនុក្រឹត្យមានលក្ខណៈសាមញ្ញ ដើម្បីធ្វើចំណាត់ថ្នាក់ទ្រព្យសម្បត្តិរបស់រដ្ឋ ហើយពុំគោរពតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ដើម្បីឆ្លងកាត់រដ្ឋសភាជាមុនសិននោះទេ។ ប្រការនេះ បណ្តាលឲ្យមានការធ្វើចំណាត់ថ្នាក់ដីដោយបំពាននៅក្នុងប្រទេសកម្ពុជា ដោយមានគំរូជាច្រើនរួចទៅហើយនៃដីសាធារណៈរបស់រដ្ឋ ត្រូវបានកែប្រែឲ្យទៅជាដីឯកជនរបស់រដ្ឋ និងក្រោយមកត្រូវបានរដ្ឋាភិបាលផ្តល់ទៅឲ្យក្រុមហ៊ុនឯកជនសម្រាប់ធ្វើការអភិវឌ្ឍ។

**សេចក្តីសន្និដ្ឋាន/អនុសាសន៍**

ករណីផ្អែកខ្លាំងពេកលើលិខិតុបករណ៍គតិយុត្តដែលមានតម្លៃទាប បានធ្វើឲ្យប៉ះពាល់ដល់កិច្ចធានា និងផលប៉ះពាល់វិជ្ជមាននៃច្បាប់ដែលមានតម្លៃខ្ពស់ និងនីតិវិធីអនុម័តតាមច្បាប់របស់ខ្លួន។ ប្រការនេះនាំឲ្យមានក្តីបារម្ភ ជាពិសេសនៅពេលដែលលិខិតុបករណ៍គតិយុត្តដែលមានកម្រិតទាប ត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងលើបញ្ហាដែលប៉ះពាល់ដល់ស្ថានភាពសិទ្ធិមនុស្ស។ ការបន្តអនុវត្តបែបនេះ ចាំបាច់ត្រូវតែបញ្ឈប់ដើម្បីបង្ការករណីរំលោភអំណាចបន្ថែមទៀត។ ម.ស.ម.ក សូមអំពាវនាវឲ្យរដ្ឋាភិបាលអនុវត្តតាមនីតិវិធីអនុម័តច្បាប់ផ្លូវការដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដោយសារតែបញ្ហានេះពិតជាមានសារៈសំខាន់ដល់លទ្ធិប្រជាធិបតេយ្យដែលរឹងមាំ និងគោលការណ៍នីតិរដ្ឋ។

**សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង លោក ឌុច ពិសិដ្ឋ តាមរយៈទូរសព្ទ៖ +៨៥៥(០) ១២ ៧១ ២៣ ៧១ ឬអ៊ីម៉ែល៖ duchpiseth@cchrcambodia.org ឬលោកស្រី អេលីស ទីឡែត តាមរយៈទូរសព្ទ៖ +៨៥៥(០) ៧៧ ៧០ ៩៧ ២៣ ឬអ៊ីម៉ែល៖ elise.tillet@cchrcambodia.org**។